២ពង្សាវតារក្សត្រ៦:១-៣៣

# ជំពូក ៦

***ធាតុចនា*** *ផ្លែពូថៅអណ្តែត*

*ភូមិជួរថានជាកន្លែងមានគ្រោះថ្នាក់*

នៅក្នុងជំពូក៦ មានបរិយាយអំពីហេតុការណ៍ពីរយ៉ាងទៀត ដែលហោរាអេលីសេបានធ្វើ។ ហោរាអេលីសេ ជាអ្នកសំណព្វរបស់ព្រះ មានចរិយាសម្បត្តិយ៉ាងល្អវិសេស។ ហោរាអេលីយ៉ា ដែលជាម្ចាស់លោក តែងតែធ្វើការអស្ចារ្យនៅទីសាធារណៈ។ ចំណែកហោរាអេលីសេវិញ ច្រើនធ្វើការអស្ចារ្យជាមួយនឹងបុគ្គលផ្ទាល់។ កន្លងមកយើងទើបនឹងឃើញហេតុការណ៍ ដែលលោកបានធ្វើការអស្ចារ្យជាមួយនឹងឧត្តមសេនីយ៍ណាម៉ាន់ ជារដ្ឋមន្ត្រីក្រសួងការពារជាតិប្រទេសស៊ីរី។ ហោរាអេលីសេធ្វើការអស្ចារ្យធំៗជាច្រើន ដូចជា សុំភ្លើង និងទឹកភ្លៀង អោយធ្លាក់ពីស្ថានសួគ៌ជាដើម។ លោកជាមនុស្សស្ងាត់ស្ងៀម។ សាធារណជនមិនសូវស្គាល់លោកទេ។ ហោរាអេលីយ៉ា និងហោរាអេលីសេ សុទ្ធតែជាអ្នកសំណព្វរបស់ព្រះ គ្រាន់តែធ្វើការខុសផ្នែកគ្នា និងជំនាន់ខុសគ្នាប៉ុណ្ណោះ។

## ផ្លែពូថៅអណ្តែតទឹក

ហេតុការណ៍ដែលហោរាអេលីសេ បានធ្វើអោយផ្លែពូថៅអណ្តែតចេញពីទឹក ជាហេតុការណ៍ដែលសម្តែងចរិយាសម្បត្តិ និងទឹកចិត្តរបស់ហោរាអេលីសេ ។

**គ្រានោះ ពួកសិស្សរបស់ពួកហោរា គេជំរាបដល់អេលីសេថា សូមមើល ទីកន្លែងដែលយើងខ្ញុំនៅជាមួយនឹងលោកនេះ ចង្អៀតដល់យើងខ្ញុំពេកណាស់ (២ពង្សាវតារក្សត្រ៦:១)។**

ហោរាអេលីសេមានប្រជាប្រិយភាពណាស់។ លោកជាគ្រូបង្ហាត់បង្រៀនដល់ពួកហោរារបស់ព្រះ នៅសាលាសិក្ខាបទមួយ។ សាលារបស់លោករីកចម្រើនរហូតដល់រកកន្លែងដាក់សិស្សមិនបាន។ លោកពូកែបង្រៀនព្រះបន្ទូលរបស់ព្រះណាស់។ សាលាដែលល្បីល្បាញ មិនមែនស្ថិតនៅលើអគារ ឬប្រដាប់ប្រដារប្រើប្រាស់ទេ គឺស្ថិតនៅលើភាពប៉ិនប្រសប់របស់គ្រូដែលបង្ហាត់បង្រៀននៅសាលានោះវិញ ពិសេសបើសាលានោះជាសាលាគ្រីស្ទបរិស័ទ។

នៅពេលដែលសិស្សសាលារកកន្លែងអង្គុយគ្មាន សិស្សទាំងនោះមានគំនិតផ្តួចផ្តើមក្នុងការពង្រីកសាលារៀនរបស់ខ្លួនអោយបានធំឡើង។

**សូមបើកឱ្យយើងខ្ញុំទៅឯទន្លេយ័រដាន់ កាប់យកឈើមួយដើមម្នាក់ ធ្វើជាទីអាស្រ័យនៅទីនោះ លោកឆ្លើយថា ចូរទៅចុះ (២ពង្សាវតារក្សត្រ៦:២)។**

សិស្សសាលាគម្ពីរនាំគ្នាផ្តើមគំនិត ដើម្បីពង្រីកសាលារបស់ខ្លួន។ ការផ្តួចផ្តើមគំនិតបែបនេះ សព្វថ្ងៃមិនឃើញមាននៅក្នុងពួកសិស្សសាលាគម្ពីរ ទោះនៅប្រទេសណាក្តី។ សិស្សសាលាគម្ពីរសព្វថ្ងៃមិនខ្វល់អំពីសាលាតូចឬធំទេ បើសាលារៀននោះមិនល្អ គេមិនមានចិត្តចង់ពង្រីកសាលាគម្ពីរដោយខ្លួនគេឡើយ គឺគេបែរជានាំគ្នាបះបោរទាស់ជាមួយនឹងរដ្ឋបាលរបស់សាលារៀន។ ចំណែកសិស្សសាលាគម្ពីរ ដែលរៀនជាមួយហោរាអេលីសេ មានគំនិតផ្តួចផ្តើម ដើម្បីពង្រីកសាលារបស់ខ្លួន។ ហោរាអេលីសេជំរុញសិស្សរបស់លោកអោយចេះធ្វើការនោះ។

**មានម្នាក់និយាយថា សូមលោកអញ្ជើញទៅជាមួយនឹងយើងខ្ញុំប្របាទផង លោកតបថា អញនឹងទៅដែរ (២ពង្សាវតារក្សត្រ ៦:៣)។**

ពួកសិស្សស្រឡាញ់ហោរាអេលីសេណាស់។ ធម្មតាសិស្សសាលាគម្ពីរមិនចូលចិត្តគ្រូបង្រៀនរបស់ខ្លួនទេ។ គេតែងតែនាំគ្នាដាក់ឈ្មោះគ្រូនីមួយៗថាយ៉ាងនេះ ឬយ៉ាង

នោះ ទៅតាមគំនិតរបស់គេ។ សិស្សសាលាគម្ពីរដែលរៀនជាមួយហោរាអេលីសេ ចង់អោយគ្រូរបស់ខ្លួនទៅជាមួយ នៅទីណាដែលគេទៅ។

**ដូច្នេះ លោកក៏ទៅជាមួយ លុះគេបានទៅដល់ទន្លេយ័រដាន់ហើយ នោះក៏កាប់ឈើ (២ពង្សាវតារក្សត្រ៦:៤)។**

នៅពេលនោះមានហេតុការណ៍អាក្រក់តូចមួយកើតឡើង។ ខ្ញុំនិយាយថា ហេតុការណ៍អាក្រក់ "តូចមួយ" ពីព្រោះអ្នកផងទាំងពួងតែងតែយល់ថា រឿងនេះមិនរាប់ថា ជារឿងធំទេ។

**តែកាលម្នាក់កំពុងតែកាប់ នោះផ្លែពូថៅបានរបូតធ្លាក់ទៅក្នុងទឹក រួចអ្នកនោះស្រែកឡើងថា វរហើយ លោកម្ចាស់ខ្ញុំអើយ ដ្បិតពូថៅនេះខ្ញុំបានខ្ចីមកពីគេ (២ពង្សាវតារក្សត្រ៦:៥)។**

ហេតុការណ៍ខាងលើ សម្តែងថាព្រះជាម្ចាស់យកព្រះទ័យទុកដាក់ជាមួយនឹងព្រឹត្តិការណ៍តូចតាច ដែលកើតមានឡើងនៅក្នុងជីវិតរបស់យើង។ សាវ័កប៉ុលសូមអោយពួកជំនុំនៅទីក្រុងភីលីព អធិស្ឋានគ្រប់រឿងអ្វីៗទាំងអស់សម្រាប់លោក។ ចំណុចនេះលោកចង់អោយពួកជំនុំ កុំភ្លេចអធិស្ឋានដល់លោកនូវគ្រប់ទាំងហេតុការណ៍តូច

តាចនៅក្នុងជីវិតដែលលោកជួបប្រទះ។

បច្ចុប្បន្ននេះ បើអ្នកណាបាត់ផ្លែពូថៅមួយមិនរាប់ថា ជារឿងធំទេ។ ប៉ុន្តែចំពោះសិស្សសាលាគម្ពីរ កំសត់នេះ បាត់ផ្លែពូថៅមួយមិនរាប់ថាជារឿងតូចតាច។ សព្វថ្ងៃ បើយើងបាត់ផ្លែពូថៅមួយ យើងទៅផ្សារ ទិញបានមួយទៀតភ្លាម។ ចំណែកសម័យហោរាអេលីសេ ឧបករណ៍ប្រើប្រាស់ ឬអាវុធដែលធ្វើពីដែក កម្រមានណាស់។ គម្ពីរ១សាំយូអែលសម្តែងអំពីភាពក្រខ្សត់នៃឧបករណ៍ប្រើប្រាស់ និងអាវុធយុទ្ធភណ្ឌដែលធ្វើពីដែក។ គម្ពីរ១សាំយូអែល១៣:២២ចែងថា "ដូច្នេះ នៅថ្ងៃចំបាំង នោះគ្មានអ្នកណាមួយ ខាងសូល នឹងយ៉ូណាថាន ដែលមានដាវ ឬលំពែងកាន់នៅដៃឡើយ ឃើញមានតែសូល ហើយនឹងយ៉ូណាថាន ជាបុត្រាទ្រង់ប៉ុណ្ណោះ"។ ពួកពលទ័ពទាំងកងមានអាវុធដែលធ្វើពីដែកតែពីរដើមប៉ុណ្ណោះ។ ដូច្នេះ ការបាត់ផ្លែពូថៅ ដោយធ្លាក់ទៅក្នុងទឹក ជារឿងធំប៉ុនមេឃសម្រាប់សិស្សសាលាគម្ពីរមួយរូបនេះ។ ម្យ៉ាងទៀតពូថៅនេះគាត់ខ្ចីគេមកផង។

សូមលោកអ្នកកុំបន្ទោសដល់សិស្សសាលាគម្ពីរម្នាក់នេះថា ហេតុអ្វីក៏ហ៊ានខ្ចីពូថៅគេ ហើយម្យ៉ាងទៀត ហេតុអ្វីក៏ប្រហែសបណ្តោយអោយពូថៅរបូតចេញពីដង។ សិស្សសាលាគម្ពីររូបនេះ មិនមានកំហុសយ៉ាងដូច្នោះទេ ដ្បិតហោរាអេលីសេដែលជាគ្រូមិនបានបន្ទោសសិស្សសាលាគម្ពីររូបនេះ សូម្បីបន្តិចសោះ។ សិស្សសាលាគម្ពីររូបនេះប្រយ័ត្នខ្លាំងណាស់ ពីព្រោះបើផ្លែពូថៅរបូតពីដង រួចហើយហើរទៅមុតនរណាម្នាក់គាត់ត្រូវទោស។ ហេតុការណ៍នេះមានគ្រោះថ្នាក់ខ្លាំងណាស់ បានជាព្រះជាម្ចាស់

ធ្វើជាច្បាប់ឡើងអោយលោកម៉ូសេកត់ទុកសម្រាប់អនុវត្ត។ ព្រះអង្គបង្គាប់នៅក្នុងគម្ពីរចោទិយកថា១៩:៤-៥ថា "នេះជាច្បាប់ខាងឯអ្នកដែលសំឡាប់គេ ហើយរត់ទៅជ្រកអាស្រ័យនៅទីក្រុងនោះ ដើម្បីនឹងឱ្យរួចជីវិតបាន គឺអ្នកណាមួយដែលសំឡាប់អ្នកជិតខាងខ្លួន មិនប្រកបដោយចិត្តប៉ង ក៏មិនបានស្អប់កាលពីមុនដែរ។ ឧបមាដូចជាមនុស្សណាម្នាក់ ដែលទៅព្រៃកាប់ឧសជាមួយនឹងអ្នកជិតខាងខ្លួន ហើយក៏លើកពូថៅឡើងនឹងកាប់រំលំដើមឈើ ស្រាប់តែផ្លែរបូតចេញពីដង ទៅត្រូវអ្នកជិតខាងដល់ស្លាប់ ដូច្នេះត្រូវឱ្យអ្នកនោះរត់ទៅជ្រកអាស្រ័យនៅទីក្រុងណាមួយនោះឱ្យបានរួចជីវិតចុះ"។ ព្រះជាម្ចាស់ធ្វើជាច្បាប់នេះឡើង ពីព្រោះករណីនេះ មានជារឿយៗ។ សិស្សសាលាគម្ពីររូបនេះប្រយ័ត្នណាស់ ដ្បិតលោកគិតគូរអំពីសុវត្ថិភាពរបស់សិស្សដទៃទៀត។ លោកបែរមុខទៅឯទន្លេយ័រដាន់ នៅពេលកាប់រំលំដើមឈើ។ បើផ្លែពូថៅរបូត អោយវារបូតធ្លាក់ចូលទៅក្នុងទឹកទន្លេចុះ។ សិស្សសាលាគម្ពីរមួយរូបនេះ ជាអ្នកប្រយ័ត្នប្រយែងខ្លាំងណាស់ សូមលោកអ្នកកុំបន្ទោសថាលោកជាអ្នកធ្វើប្រហែសឡើយ។

មួយទៀត មានគេរិះគន់លោកថា ហេតុអ្វីបានជាលោកហ៊ានខ្ចីពូថៅគេ។ សិស្សសាលាគម្ពីរមួយរូបនេះក្រខ្សត់ណាស់ មិនអាចទិញផ្លែពូថៅមួយសម្រាប់យកមកប្រើខ្លួនឯងបានទេ។ កាលខ្ញុំនៅរៀនសាលាគម្ពីរ ខ្ញុំជិះឡានកញ្ចាស់ៗអស់ចំនួនបីគ្រឿងក្នុងរយៈពេលប្រាំឆ្នាំ។ ខ្ញុំត្រូវបើកឡានទាំងនោះពីររយគីឡូម៉ែត្រក្នុងមួយថ្ងៃ ដើម្បីទៅនឹងមកពីសាលារៀន។ ខ្ញុំចង់បានឡានថ្មីជិះនឹងគេដែរ ប៉ុន្តែសិស្សសាលាគម្ពីរកម្រមាន

លុយទិញឡានថ្មីណាស់។ ដូច្នេះខ្ញុំមិនបន្ទោសដល់សិស្សសាលាគម្ពីររូបនោះថា ហេតុអ្វីក៏មិនទិញពូថៅប្រើខ្លួនឯង។

សំណួរដែលខ្ញុំចង់សួរវិញ ថាតើជនណាមួយដែលអោយសិស្សសាលាគម្ពីរខ្ចីពូថៅកញ្ចាស់ដែលមានផ្លែចង់របូតពីដងយកទៅប្រើ ដើម្បីសង់សាលាគម្ពីរ? ខ្ញុំចង់រកមុខមនុស្សនោះណាស់។ មនុស្សនោះប្រហែលជាអ្នកដែលធ្វើការល្អសម្រាប់ព្រះជាម្ចាស់ ដោយយកខោអាវស្អុយ និងរបស់ប្រើប្រាស់មិនកើតយកទៅបោះចោលនៅក្នុងព្រះវិហារ ដោយគិតថា ថ្វាយដល់ព្រះជាម្ចាស់។ មនុស្សនោះ គួរទទួលការបន្ទោសច្រើនជាងបន្ទោសដល់សិស្សសាលាគម្ពីរ ដែលទៅខ្ចីពូថៅយកមកប្រើប្រាស់។

សិស្សសាលាគម្ពីររូបនេះពិបាកចិត្តណាស់ ពីព្រោះមិនដឹងថា ត្រូវទៅរកពូថៅពីណា យកមកជូនម្ចាស់គេវិញ។ ហោរាអេលីសេយល់អំពីទុក្ខលំបាករបស់សិស្សលោក។ លោកដណ្តឹងសួរដល់សិស្សនោះថា "តើធ្លាក់ត្រង់ណា?" អ្នកខ្លះធៀតបន្ទោសហោរាអេលីសេថា បើលោកជាហោរារបស់ព្រះពិតប្រាកដមែន លោកត្រូវតែដឹងថា កន្លែងណាដែលពូថៅនោះធ្លាក់លិចចូលទៅក្នុងទឹក។ ព្រះវិញ្ញាណរបស់ព្រះ ជ្រាបច្បាស់ថា នៅក្នុងសតវត្សរ៍ទីម្ភៃមួយយើងនេះ មានមនុស្សដែលរិះគន់ដល់ការអស្ចារ្យ ដែលហោរាអេលីសេបានធ្វើ ស្តីអំពីផ្លែពូថៅអណ្តែតទឹក។ អ្នកប្រកាន់គោលទ្ធិព្រះគម្ពីរបែបសេរីនិយមសព្វថ្ងៃគេនិយាយថា ហោរាអេលីសេមើលឃើញផ្លែពូថៅធ្លាក់ចូលទៅក្នុងទឹក ពីព្រោះទឹកទន្លេយ័រដាន់ថ្លាឆ្វង់។ ទន្លេយ័រដាន់មិនមែនមានទឹកថ្លាឆ្វង់ទេ។ ទន្លេយ័រដាន់មានកករល្បប់យ៉ាងច្រើន ឯទឹកទៀតសោតក៏ល្អក់ខ្វរអណ្តែង។ ទឹកទន្លេយ័រដាន់

លាយឡំទៅដោយសំរាម ដែលអ្នកស្រុកធ្វើអោយទឹកនោះទៅជាកខ្វក់។ សិស្សសាលាគម្ពីរមួយរូបនេះដឹងច្បាស់ថា ផ្លែពូថៅធ្លាក់នៅទីណា ប៉ុន្តែ លោកមិនអាចទៅរកពូថៅនោះឃើញ ព្រោះទឹកល្អក់ខ្លាំងពេក។ ហោរាអេលីសេសួរថា "តើធ្លាក់ត្រង់ណា?"

**អ្នកសំណប់របស់ព្រះសួរថា តើធ្លាក់ត្រង់ណា អ្នកនោះក៏បង្ហាញកន្លែង រួចលោកកាប់មែកឈើ១កំណាត់ បោះទៅក្នុងទឹក ហើយផ្លែពូថៅក៏អណ្តែតឡើងមក (២ពង្សាវតារក្សត្រ៦:៦)។**

ហេតុការណ៍ដែលកើតឡើងខាងលើ គឺជាការអស្ចារ្យ។ ការអស្ចារ្យនេះ មិនមានលក្ខណៈដូចជារាជរថជាភ្លើង ដែលទឹមដោយសេះជាភ្លើងហោះមកនោះទេ។ ការអស្ចារ្យនេះ កើតឡើងសាមញ្ញជាទីបំផុត។ ឯភាពសាមញ្ញនេះទៀតសោត គឺដុំដែកអណ្តែតទឹក។ ហេតុការណ៍អស្ចារ្យនេះ ផ្ទុយអំពីច្បាប់នានា ស្តីអំពីរូបមន្តធម្មជាតិដែរថា គ្រឿងដែកត្រូវតែលិចទឹក។ ម្យ៉ាងទៀតខ្ញុំយល់ដែរ ថាសព្វថ្ងៃមានដែករាប់តោនដែលអណ្តែតលើទឹក។ ឯដែកនោះគឺជាកប៉ាល់ដែលធ្វើដំណើរឆ្លងមហាសាគរ។ កប៉ាល់អណ្តែតទឹក មិនមែនជាការអស្ចារ្យទេ។ ការអស្ចារ្យ គឺផ្លែពូថៅមួយដែលធ្លាក់ចូលទៅដល់បាតទន្លេយ័រដាន់ទៅហើយ បែរជាអណ្តែតដូចស្នោ។ ហោរាអេលីយ៉ាយកចិត្តទុកដាក់ជាមួយនឹងទុក្ខកង្វល់របស់សិស្សលោកណាស់ សូម្បីទុក្ខកង្វល់នោះ តូចតាចប៉ុនណាក៏ដោយ។

ការអស្ចារ្យទាក់ទងជាមួយនឹងផ្លែពូថៅអណ្តែតទឹក បន្សល់ទុកនូវមេរៀនខាងព្រលឹងវិញ្ញាណសម្រាប់យើងយកមកអនុវត្ត។ ផ្លែពូថៅដែលរបូតពីដងត្រូវធ្លាក់កប់ភក់នៅក្នុងទន្លេយ័រដាន់។ ប៉ុន្តែ ផ្លែពូថៅនេះ ត្រូវអណ្តែតឡើងមកវិញ រួចហើយគេចាប់យកដាក់ដងសារជាថ្មី ដើម្បីអាចប្រើប្រាស់បានជាបន្តទៅទៀត។ មនុស្សគ្រប់រូបប្រៀបឧបមាដូចជាផ្លែពូថៅ ដែលលិចទៅក្នុងទឹក។ មនុស្សទាំងអស់បានរបូតចេញពីដងដែលព្រះជាម្ចាស់បានបង្កើតមក។ ចិត្តគំនិតរបស់គេធ្លាក់ពីសណ្ឋានដើម ដើរវង្វេងវង្វាន់គ្មានទិសដៅនៅក្នុងលោកសន្និវាស។

នៅពេលដែលហោរាអេលីសេដឹងថា ពូថៅធ្លាក់ត្រង់ណាហើយ លោកក៏កាត់ឈើមួយដុំបោះទៅចំកន្លែងដែលផ្លែពូថៅនោះធ្លាក់ចុះ។ តើឈើនោះគឺជាឈើអ្វី? ឈើនោះ គឺជាឈើឆ្កាងរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទទ្រង់យាងចុះពីស្ថានសួគ៌មក ដើម្បីសុគតនៅលើឈើឆ្កាង។ ទ្រង់យាងមកសុគតនៅលើឈើឆ្កាងដើម្បីស្រង់យើងចេញពីទឹកនៃសេចក្តីស្លាប់។ គម្ពីរ១ពេត្រុស២:២៤ ចែងថា "ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ជាប់លើឈើឆ្កាង ដើម្បីឱ្យយើងបានរស់ខាងឯសេចក្តីសុចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ គឺដោយស្នាមជាំរបស់ទ្រង់ ដែលអ្នករាល់គ្នាបានជា"។

សព្វថ្ងៃនេះ មនុស្សគ្រប់រូបអាចងើបពីទឹកនៃសេចក្តីស្លាប់ និងសេចក្តីជំនុំជំរះតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ជនណាដែលទទួលជឿដល់ព្រះអម្ចាស់យេស៊ូវថាជាអង្គសង្គ្រោះ ទ្រង់បានយកអ្នកនោះទៅដាក់ដងអោយត្រូវនឹងផែនការ និងវត្ថុបំណង

ដើមដែលព្រះជាម្ចាស់បង្កើតមកអោយរស់នៅលើផែនដី។ សាវ័កប៉ុលធ្វើទីបន្ទាល់ថា "ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រិស្តដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ" (ភីលីព៤:១៣)។ មិនតែប៉ុណ្ណោះ សាវ័កប៉ុលបញ្ជាក់បន្ថែមទៀតថា "បងប្អូនអើយ ខ្ញុំមិនរាប់ថាខ្លួនខ្ញុំចាប់បានហើយនោះទេ តែមានសេចក្តីនេះ១ គឺថាខ្ញុំភ្លេចសេចក្តីទាំងប៉ុន្មានដែលកន្លងទៅហើយ ក៏ខំមមុលឈោងទៅឯសេចក្តីខាងមុខទៀត ទាំងរត់ដំរង់ទៅឯទី ដើម្បីឱ្យបានរង្វាន់នៃការងារដ៏ខ្ពស់របស់ព្រះក្នុងព្រះគ្រិស្តយេស៊ូវ" (ភីលីព៣:១៣-១៤)។ មនុស្សគ្រប់រូបមិនចាំបាច់រស់ក្នុងជីវិតឥតន័យទៀតទេ។ ជីវិតឥតន័យនាំអោយមនុស្សរាប់ពាន់រាប់ម៉ឺននាក់ សម្រេចចិត្តសម្លាប់ខ្លួនឯង។ មែនហើយ! បើលោកអ្នកយល់ថា លោកអ្នកជាផ្លែព្ធថៅធ្លាក់កប់ភក់ក្នុងទន្លេយ័រដាន់ លោកអ្នកពិតជាគ្មានតម្លៃអ្វីមែន។ ប៉ុន្តែ បើលោកអ្នកយល់ថា លោកអ្នកជាមនុស្សគ្មានតម្លៃ បែរមកទទួលព្រះអម្ចាស់យេស៊ូវដែលសុគតនៅលើឈើឆ្កាង ព្រះជាម្ចាស់នឹងលាងលោកអ្នក រួចហើយយកទៅដាក់ដងដែលជាផែនការ និងវត្ថុបំណងដើមរបស់ទ្រង់។ ដោយសារការនោះ ជីវិតលោកអ្នកមានតម្លៃ ដូចព្រះអម្ចាស់ទ្រង់បានបង្កើតលោកអ្នកពីដើមដំបូងកន្លងមក។ ខ្ញុំជួបជាមួយនឹងយុវជនម្នាក់ ដែលអាយុមិនទាន់បានម្ភៃមួយឆ្នាំផង។ យុវជននោះនិយាយថា "ជីវិតរបស់ខ្ញុំតែងតែទទួលបរាជ័យជានិច្ច"។ ខ្ញុំឆ្លើយថា "ឯងមិនទាន់ដល់អាយុដែលចាប់ផ្តើមជីវិតផង ហេតុដូចម្តេចបានជាឯងនិយាយថា ជីវិតឯងទទួលបរាជ័យ?" សព្វថ្ងៃនេះ យើងត្រូវការព្រះជាម្ចាស់ ដើម្បីបំផ្លាស់បំប្រែអោយជីវិតយើងមានន័យ។ ការអស្ចារ្យធំបំផុតដែលមានឡើងដល់ជីវិតរបស់មនុស្ស មិនចាំបាច់អោយ

យើងជិះយានអវកាសទៅស្ថានព្រះចន្ទទេ។ ម្យ៉ាងទៀត ការអស្ចារ្យនៅក្នុងជីវិតមិនមែនជាការជិះរាជរថជាភ្លើង សេះជាភ្លើងដែរ។ ការអស្ចារ្យសម្រាប់ជីវិតមនុស្សលោកគឺទទួលស្គាល់ថា យើងជាមនុស្សមានបាប រួចហើយយាងព្រះអម្ចាស់យេស៊ូវគ្រីស្ទ មកគង់នៅក្នុងចិត្តរបស់យើង។ សកម្មភាពនោះ រាប់ថាជាការអស្ចារ្យ។ នៅពេលដែលយើងទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទ ទ្រង់លើកយើង រួចហើយលាងយើងអោយជ្រះពីភក់ជ្រាំនៃអំពើបាប បង្កើតយើងអោយទៅជាមនុស្សថ្មី ដើម្បីអោយយើងអាចរស់ក្នុងជីវិតថ្លៃថ្នូរថ្វាយសិរីល្អដល់ព្រះជាម្ចាស់។

**នោះលោកបង្គាប់ថា ចូរចាប់យកចុះ អ្នកនោះក៏លូកដៃទៅចាប់យកមក (២ពង្សាវតារក្សត្រ៦:៧)។**

យើងត្រូវលូកដៃទៅចាប់យកសេចក្តីសង្គ្រោះរបស់ព្រះអម្ចាស់យេស៊ូវ ដោយជំនឿ។ ព្រះអង្គសុគតជំនួសលោកអ្នកបងប្អូន ព្រមទាំងរស់ឡើងវិញ ដើម្បីលាងលោកអ្នកអោយស្អាតអំពើបាប ព្រមទាំងរាប់លោកអ្នកថាជាមនុស្សសុចរិត។ លោកអ្នកចាំបាច់ត្រូវលូកដៃ ដើម្បីទទួលយកសេចក្តីសង្គ្រោះដែលព្រះអម្ចាស់ប្រទានដល់លោកអ្នកដោយជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

## ត្រូវមិជូរថាន់ជាកន្លែងមានគ្រោះថ្នាក់

ស្តេចស្រុកស៊ីរីតែងតែជិះជាន់សាសន៍អ៊ីស្រាអែលជានិច្ច។ ទំនាស់រវាងនគរអ៊ីស្រាអែល និងនគរស៊ីរី មានតាំងពីយូរណាស់មកហើយ។ សាសន៍ស៊ីរី គឺជាសាសន៍អារ៉ាប់។ ទំនាស់រវាងអ៊ីស្រាអែលនិងអារ៉ាប់ ដែលយើងឃើញមានក្នុងពេលបច្ចុប្បន្ននេះ មានតាំងពីគ្រាសម័យព្រះគម្ពីរម្ល៉េះ។ សូមយើងសង្កេតមើលហេតុការណ៍ដែលកើតឡើងដូចខាងក្រោមនេះ។

**[៨]រីឯស្តេចស្រុកស៊ីរី ទ្រង់កំពុងតែច្បាំងនឹងសាសន៍អ៊ីស្រាអែល ក៏**
**ហៅពួកអ្នកជំនិតទ្រង់មកពិគ្រោះគ្នា រួចបង្គាប់ថា យើងនឹងបោះ**
**ទ័ពនៅទីណាមួយនោះ [៩]ដូច្នេះ អ្នកសំណប់របស់ព្រះ លោកចាត់**
**គេឱ្យទៅទូលដល់ស្តេចអ៊ីស្រាអែលថា សូមទ្រង់ប្រយ័ត កុំយាង**
**ទៅតាមទី១នោះឡើយ ដ្បិតពួកស៊ីរីគេចុះមកតាមផ្លូវនោះហើយ**
**[១០]ស្តេចអ៊ីស្រាអែលក៏ចាត់គេ ឱ្យទៅឯកន្លែងណាដែលអ្នកសំណប់**
**របស់ព្រះបានប្រាប់ឱ្យប្រយ័តនោះ ទ្រង់ក៏បានរួចពីសេចក្តីអន្តរាយ**
**នៅទីទាំងនោះ មិនមែនតែម្តង ឬពីរដងប៉ុណ្ណោះទេ [១១]ឯស្តេច**
**ស្រុកស៊ីរី ទ្រង់មានព្រះទ័យវល់អំពីដំណើរនោះ ក៏ហៅពួកអ្នក**
**ជំនិតមកសួរថា តើអ្នករាល់គ្នាមិនព្រមប្រាប់ឱ្យយើងដឹងជាអ្នក**

**ណាក្នុងពួកយើង ដែលកាន់ខាងស្តេចអ៊ីស្រាអែលទេឬ (២ពង្សាវតារក្សត្រ៦:៨-១១)។**

ស្តេចនគរស៊ីរីចេះតែឆ្ងល់ថា ហេតុអ្វីបានជាពេលដែលលោកធ្វើផែនការសង្គ្រាម ស្តេចសាសន៍អ៊ីស្រាអែលជ្រាបទាំងអស់។ ទ្រង់ក៏ស៊ើបសួរក្រែងលោមានគិញសម្ងាត់ណាមួយ ដែលបញ្ជូនផែនការរបស់ទ្រង់អោយសាសន៍អ៊ីស្រាអែលដឹង។ តាមពិតអ្នកជំនិតគ្រប់រូបរបស់ស្តេចស្រុកស៊ីរីមានការស្មោះត្រង់ជាមួយនឹងទ្រង់ណាស់។

**នោះអ្នកជំនិតទ្រង់ម្នាក់ទូលតបថា បពិត្រព្រះករុណា ជាព្រះអម្ចាស់នៃទូលបង្គំអើយ ឥតមានអ្នកណាឡើយ គឺជាអេលីសេជាហោរា ដែលនៅស្រុកអ៊ីស្រាអែលវិញ គាត់នាំយកអស់ទាំងព្រះបន្ទូល ដែលទ្រង់មានបន្ទូល នៅក្នុងក្រឡាព្រះបន្ទំរបស់ទ្រង់ទៅប្រាប់ដល់ស្តេចអ៊ីស្រាអែល (២ពង្សាវតារក្សត្រ៦:១២)។**

អ្នកដែលដឹងរឿងរ៉ាវទាំងអម្បាលមាណ គឺហោរាអេលីសេ។ គំនិតដែលស្តេចស្រុកស៊ីរីគិតនៅលើគ្រែ ក៏ហោរាអេលីសេដឹងដែរ។ ហោរាអេលីសេអាចដឹងពីការសម្ងាត់ទាំងនោះ ពីព្រោះព្រះអម្ចាស់បានបើកសម្តែងអោយលោកដឹង។

លុះស្តេចស៊ីរីជ្រាបថា ហោរាអេលីសេជាអ្នកផ្តល់ព័ត៌មានពីសង្គ្រាមដល់

ស្តេចសាសន៍អ៊ីស្រាអែល ស្តេចស៊ីរីចង់ចាប់ហោរាអេលីសេយកទៅប្រហារជីវិត។ ហោរាអេលីសេស្នាក់នៅភូមិដូរថាន់ គឺជាភូមិដែលនៅឆ្ងាយប្រមាណកៅសិបប្រាំមួយគីឡូម៉ែត្រខាងជើងទីក្រុងយេរូសាឡិម។ ដូរថាន់ ប្រែថា អណ្តូងភ្លោះ។ មានវាលស្មៅយ៉ាងធំទូលាយដែលអ្នកផងទាំងពួងតែងតែយកគោ ក្របី ចៀម ពពែ ទៅឃ្វាលនៅទីនោះ។ ស្តេចស្រុកស៊ីរីបញ្ជូនកងទ័ពដែលមានទ័ពសេះរទេះចម្បាំងយ៉ាងច្រើន មកព័ទ្ធភូមិដូរថាន់ ដើម្បីចាប់ហោរាអេលីសេ។ ពួកសិស្សរបស់ហោរអេលីសេម្នាក់បានចេញទៅក្រៅភូមិ រួចហើយជួបប្រទះជាមួយនឹងកងទ័ពដ៏ច្រើនសន្ធឹកសន្ធាប់។ សិស្សសាលាព្រះគម្ពីររូបនោះត្រឡប់មកជួបជាមួយនឹងហោរាអេលីសេជម្រាបថា "វរហើយ ចៅហ្វាយខ្ញុំអើយ តើយើងនឹងធ្វើដូចម្តេច?"

**លោកឆ្លើយតបថា កុំខ្លាចអ្វីឡើយ ដ្បិតពួកដែលនៅខាងយើងមានគ្នាច្រើនជាងពួកដែលនៅខាងគេទៅទៀត (២ពង្សាវតារក្សត្រ៦:១៦)។**

ពាក្យដែលហោរាអេលីសេមានប្រសាសន៍នេះ ហាក់ដូចជាមិនពិតប្រាកដទេ ពីព្រោះកងទ័ពស្តេចស្រុកស៊ីរីមានច្រើនមីរដេរដាស់។ ហោរាអេលីសេមានតែសិស្សរបស់លោកមួយក្តាប់តូចប៉ុណ្ណោះ។ ពួកសិស្សនាំគ្នាខ្លាចស្ទើរស្លាប់។ ដូច្នេះ ហោរាអេលីសេក៏អធិស្ឋានទូលដល់ព្រះជាម្ចាស់។

> **នោះអេលីសេក៏អធិស្ឋានថា ឱព្រះយេហូវ៉ាអើយ សូមទ្រង់ប្រោសឱ្យភ្នែកវាបានមើលឃើញ ព្រះយេហូវ៉ាទ្រង់ក៏ប្រោសភ្នែកអ្នកបំរើនោះ ហើយវាក៏មើលទៅឃើញភ្នំនោះ មានពេញដោយពលសេះនឹងរទេះចំបាំង ដែលសុទ្ធតែជាភ្លើង នៅព័ទ្ធជុំវិញអេលីសេ (២ពង្សាវតារក្សត្រ៦:១៧)។**

សំណួរដែលយើងគួរសួរថា តើព្រះជាម្ចាស់ការពារស្រ្តរបស់ព្រះអង្គដូចទ្រង់ការពារដល់ហោរាអេលីសេរហូតឬ?

គ្រីស្ទបរិស័ទខ្លះ ជួបជាមួយនឹងបទពិសោធន៍ដូចព្រះជាម្ចាស់ ការពារដល់ហោរាអេលីសេខាងលើនេះមែន។ ប៉ុន្តែ គ្រីស្ទបរិស័ទខ្លះទៀត មិនដែលជួបប្រទះជាមួយនឹងបទពិសោធន៍នោះទេ។ តើគ្រីស្ទបរិស័ទដែលមិនជួបប្រទះជាមួយនឹងការការពារដូចព្រះជាម្ចាស់ការពារដល់អេលីសេ ជាគ្រីស្ទបរិស័ទដែលព្រះជាម្ចាស់បោះបង់ចោលឬ? ដើម្បីឆ្លើយនឹងសំណួរនេះ សូមយើងត្រឡប់ទៅភូមិដូរថាន់។ ភូមិដូរថាន់ជាកន្លែងមានគ្រោះថ្នាក់។ នៅក្នុងគម្ពីរមានរៀបរាប់ពីភូមិដូរថាន់តែពីរដងប៉ុណ្ណោះ។

រាប់រយឆ្នាំកន្លងទៅ មានយុវជនម្នាក់អាយុដប់ប្រាំពីរឆ្នាំ បានមកដល់ភូមិដូរថាន់នេះដែរ។ ពួកបងៗបានចាប់លោកនៅភូមិដូរថាន់ ដើម្បីលក់ទៅអោយធ្វើជាខ្ញុំគេនៅស្រុកអេស៊ីព្ទ។ យុវជនយ៉ូសែប ជួបប្រទះជាមួយនឹងគ្រោះថ្នាក់យ៉ាងខ្លាំងនៅភូមិដូរថាន់ ប៉ុន្តែ លោកមិនបានឃើញរាជរថនិងសេះជាភ្លើងមកការពារលោកទេ។ ពួក

បង១ស្រង់លោកចេញពីអណ្តូងនៅភូមិដូវថាន់ រួចហើយលក់ទៅអោយធ្វើជាខ្ញុំកំដរដាច់ថ្លៃរបស់គេនៅស្រុកអេស៊ីព្ទ។ តើព្រះជាម្ចាស់ការពារយុវជនយ៉ូសែបដោយរទេះ និងសេះជាភ្លើងដែរឬ? មែនហើយ! ព្រះជាម្ចាស់ពិតជាការពារយុវជនយ៉ូសែប ដូចទ្រង់ការពារជីវិតហោរាអេលីសេ ក្នុងពេលនេះដែរ។ ព្រះជាម្ចាស់បើកសម្តែងអោយហោរាអេលីសេឃើញថា ទ្រង់ការពារលោកដោយរទេះនិងសេះជាភ្លើង។ ចំណែកលោកយ៉ូសែបវិញ ព្រះជាម្ចាស់ក៏ការពារលោកដែរ គ្រាន់តែព្រះជាម្ចាស់មិនបណ្តាលអោយលោកឃើញតែប៉ុណ្ណោះ។ ដូច្នេះ ហើយបានជាលោកអាចធានាអះអាងដល់ពួកបង១ទាំងអស់ ពេលលោកមុននឹងស្លាប់ថា "អ្នករាល់គ្នាបានគិតធ្វើអាក្រក់ដល់ខ្ញុំ តែព្រះទ្រង់សំរេចជាការល្អវិញ ដើម្បីនឹងសង្គ្រោះដល់ជីវិតនៃមនុស្សជាច្រើន ដូចជាបានកើតមានសព្វថ្ងៃនេះ" (លោកុប្បត្តិ៥០:២០)។ ភូមិដូវថាន់ជាកន្លែងមានគ្រោះថ្នាក់ ប៉ុន្តែ ព្រះជាម្ចាស់បានរៀបចំរបងការពារដល់អស់អ្នកបម្រើព្រះអង្គ ដែលជួបប្រទះគ្រោះថ្នាក់ដូចហោរាអេលីសេជួបប្រទះនៅភូមិដូវថាន់។

## ពួកពលទ័ពស៊ីរីខ្វាក់ភ្នែក

**កាលបានចុះមកដល់អេលីសេហើយ នោះលោកអធិស្ឋានដល់ព្រះយេហូវ៉ាថា សូមព្រះអង្គវាយពួកស៊ីរីនេះ ឲ្យភ្នែកគេព្រាវព្រិលទៅ ដូច្នេះ ទ្រង់ក៏ធ្វើឲ្យភ្នែកគេព្រាវព្រិលតាមពាក្យអេលីសេ (២ពង្សាវ**

**ពារក្សត្រ៦:១៨)។**

ព្រះជាម្ចាស់បណ្ដាលអោយហោរាអេលីសេ អាចធ្វើអោយភ្នែករបស់ពួកកងទ័ពស្ដេចស៊ីរីងងឹតទាំងអស់។ លោកបាននាំកងទ័ពទាំងនោះ អោយដើរតាមលោកទៅទីក្រុងសាម៉ារី ដោយប្រាប់ថា ត្រូវទៅចាប់ហោរាអេលីសេនៅទីនោះ។ នៅពេលដែលកងទ័ពទៅដល់ទីក្រុងសាម៉ារី លោកបានបើកភ្នែកអោយគេមើលឃើញវិញ។ ស្ដេចសាសន៍អ៊ីស្រាអែលចង់សម្លាប់កងទ័ពទាំងនោះ ប៉ុន្តែ ហោរាអេលីសេបានបង្គាប់ដល់ស្ដេចថា "...សូមដាក់នំបុ័ង នឹងទឹកមកនៅមុខគេ ឱ្យបរិភោគវិញ រួចឱ្យត្រឡប់ទៅឯចៅហ្វាយគេទៅ" (២ពង្សាវតារក្សត្រ៦:២២)។

**ដូច្នេះ ស្ដេចក៏ចាត់ចែងភោជនាហារយ៉ាងច្រើនឱ្យគេ កាលគេបានបរិភោគរួចហើយ នោះទ្រង់លែងឱ្យទៅវិញ ហើយគេវិលត្រឡប់ទៅឯចៅហ្វាយខ្លួនទៅ ឯសាសន៍ស៊ីរីក៏លែងទន្ទ្រានចូលក្នុងស្រុកអ៊ីស្រាអែលដោយពួក១ទៀត (២ពង្សាវតារក្សត្រ៦:២៣)។**

ក្រោយពីពេលនោះមក ស្ដេចស៊ីរីមិនបានចូលមកវាតត្បាតនគរអ៊ីស្រាអែលអស់រយៈពេលយ៉ាងយូរ។ ក្រោយមកទៀត ស្ដេចបេន-ហាដាឌ់ សម្រេចចិត្តលើកទ័ព

មកឡោមព័ទ្ធក្រុងសាម៉ារីម្ដងទៀត។

## ស្ដេចបេន-ហាដាឌ់ឡោមព័ទ្ធក្រុងសាម៉ារី

**[២៤] ក្រោយនោះមក បេន-ហាដាឌ់ ជាស្ដេចស្រុកស៊ីរី ទ្រង់ក៏ប្រមូលកងទ័ពទាំងអស់ លើកឡើងទៅឡោមព័ទ្ធច្បាំងនឹងក្រុងសាម៉ារី [២៥] ដូច្នេះ នៅក្រុងសាម៉ារីមានអំណត់អត់ជាខ្លាំង ពួកស៊ីរីឡោមព័ទ្ធច្បាំងនឹងទីក្រុងនោះ ទាល់តែក្បាលលា១លក់ថ្លៃ៨០រៀល ហើយអាចម៍ព្រាប១កំប៉ុងលក់ថ្លៃ៥រៀល (២ពង្សាវតារក្សត្រ៦:២៤-២៥)។**

នៅពេលដែលកងទ័ពនគរស៊ីរីឡោមព័ទ្ធក្រុងសាម៉ារី អ្វីៗទាំងអស់ឡើងថ្លៃកប់ពពក។ សូម្បីក្បាលលាមួយមានតម្លៃដល់ទៅប៉ែតសិបរៀល។ ប៉ែតសិបរៀល សម័យដើម មានតម្លៃស្មើនឹងមាសបីជី។ ការឡោមព័ទ្ធទីក្រុង បណ្ដាលអោយអ្នកស្រុកគ្មានម្ហូបអាហារអ្វីទទួលទាន។ ខជាបន្តបន្ទាប់រៀបរាប់អំពីមនុស្សស៊ីកូនឯង ដោយសារការខ្វះខាតម្ហូបអាហារ។

**នោះទ្រង់មានបន្ទូលស្បថថា បើក្បាលអេលីសេ កូនសាផាត នៅជាប់លើខ្លួនវានៅថ្ងៃនេះ នោះសូមឲ្យព្រះទ្រង់ប្រព្រឹត្តនឹងយើងយ៉ាងនោះវិញ ហើយលើសទៅទៀតផង (២ពង្សាវតារក្សត្រ ៦:៣១)។**

យើងមិនដឹងថា ហេតុអ្វីបានជាស្តេចដាក់ទោសដល់ហោរាអេលីសេ ដោយសារស្តេចនគរស៊ីរីមកឡោមព័ទ្ធទីក្រុងសាម៉ារីទេ។ បើតាមការសន្និដ្ឋាន ស្តេចប្រហែលជាខឹងជាមួយនឹងហោរាអេលីសេថា ហោរាអេលីសេអាចធ្វើអោយមានម្ហូបអាហារសម្រាប់ពលរដ្ឋក្នុងទីក្រុងបាន តែលោកមិនព្រមធ្វើការអស្ចារ្យនោះ។

ឆាកឈុតដែលកើតឡើងនៅក្នុងជំពូកបន្ទាប់ទៅទៀត គឺជាឆាកឈុតដែលទាក់ទងជាមួយនឹងរឿងដែលយើងទើបនឹងសិក្សាអម្បាលម៉ិញនេះ។ ហេតុការណ៍ដែលកើតឡើងនៅពេលនោះ គឺជាហេតុការណ៍យ៉ាងអស្ចារ្យ ដែលហោរាអេលីសេបានធ្វើដែរ។

យើងស្លេះការសិក្សាគម្ពីរ២ពង្សាវតារក្សត្រត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"